ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
អភិបូជាបើកឆ្នាំសិក្សាថ្មីសាលាអប់រំជំនឿសន្តយ៉ូស្ទីន
ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៧

អត្ថបទទី១៖ យអ ៤,១២-២១
ដំណឹងល្អ៖ លក ១១,២៧-២៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលមួយដ៏ល្អដើម្បីបើកឆ្នាំនេះ “**អ្នកណាស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអនុវត្តតាម គឺអ្នកនោះហើយដែលមានសុភមង្គលពិតមែន**”។ ព្រះយេស៊ូណែនាំឲ្យយើង ជានិស្សិតសាលាសន្តយ៉ូស្ទីន ឲ្យយើងយកចិត្តទុកដាក់៖

**ទីមួយ ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់** កុំឲ្យយើងយល់ថាស្តាប់ព្រះបន្ទូលព្រះជាម្ចាស់តែនៅពេលចូលអភិបូជាស្តាប់គម្ពីរម្តង។ តាមពិតនៅក្នុងគ្រប់មុខវិជ្ជាដែលលោកឪពុកនឹងបង្រៀននៅឆ្នាំនេះ ជាឱកាសមួយដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកដាមីញ៉ាំងនឹងបំភ្លឺយើងអំពីសម្ព័ន្ធមេត្រីចាស់ គឺយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ម្យ៉ាងផ្ទាល់ ប៉ុន្តែតាមមុខវិជ្ជារបស់លោកបូជាចារ្យផ្សេងក៏ដូចគ្នាដែរ ដោយសារប៉ុន្មានដងនៅពេលខ្ញុំបង្រៀនយើងអានគម្ពីរដំណឹងល្អ ឬយើងយល់នេះជាព្រះជាម្ចាស់តាមមុខវិជ្ជានីមួយៗ នៅក្នុងជីវិតព្រះយេស៊ូ ឆ្នាំនេះនៅក្នុងព្រះសហគមន៍ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងអគ្គសញ្ញាដែលខ្ញុំនឹងបង្រៀន ជាព្រះជាម្ចាស់ដែលកំពុងនិយាយដល់យើង ជាព្រះជាម្ចាស់ដែលកំពុងបំភ្លឺយើងតែម្តង តាមលោកឪពុកលីជាមួយសីលធម៌ តាមលោកឪពុកប៉ិប់ជាមួយប្រវត្តិសាស្ត្រ។ ព្រះជាម្ចាស់មានព្រះបន្ទូល នៅក្នុងប្រវត្តិសាស្ត្រព្រះសហគមន៍ទាំងអស់ ព្រះជាម្ចាស់មានព្រះបន្ទូលច្បាស់ហើយនៅក្នុងសីលធម៌ នៅក្នុងរបៀបដែលយើងរស់នៅប្រចាំថ្ងៃ។ ដូច្នេះ សម្រាប់យើងដែលជានិស្សិតសន្តយ៉ូស្ទីន យើងដឹងថារាល់ថ្ងៃសុក្រ ថ្ងៃសៅរ៍ នៅពេលយើងជួបជុំគ្នា យើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយយកចិត្តទុកដាក់ស្តាប់មេរៀន គិតអំពីមេរៀនរបស់យើង រៀបចំសំណួរ រៀបចំចម្លើយ រៀបចំប្រឡង យកចិត្តទុកដាក់អានសៀវភៅ ឬស្រាវជ្រាវតាមអ៊ីនធឺណែតថែមទៀត។ នៅក្នុងសន្តយ៉ូស្ទីន ខ្ញុំឆ្លៀតឱកាសដើម្បីរំឭកដែរ នៅថ្ងៃសៅរ៍នៅពេលយើងមានអភិបូជាពេលព្រឹក ឬនៅថ្ងៃសុក្រ ពេលល្ងាច ដែលយើងមានអធិដ្ឋាននៅទីនេះ ជាឱកាសមួយដែរដើម្បីជិតស្និទ្ធជាមួយព្រះជាម្ចាស់ និងដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែមទៀត។ នេះជាអ្វីដែលសន្តយ៉ូស្ទីនប្រគល់ឲ្យយើងជារៀងរាល់អាទិត្យ កុំឲ្យយើងភ្លេចការសិក្សាផង អភិបូជា ការអធិដ្ឋានផង នេះណែនាំឲ្យសាលារបស់យើងមានជីវិត មានជីវិតយ៉ាងត្រឹមត្រូវ និងណែនាំឲ្យសាលាយើងអាចរីកចម្រើនថែមទៀត។ ប៉ុន្តែ នេះមិនមែនតែប៉ុណ្ណឹងសំខាន់ទំនាក់ទំនងដែលយើងបង្កើតដែរ ដូច្នេះបងប្អូនដែលមានទំលាប់ភ្លេចចូលអភិបូជាថ្ងៃសៅរ៍ខ្ញុំរំឭក នេះជាកម្មវិធីនៅក្នុងសន្តយ៉ូស្ទីនតែម្តង មិនមែនកម្មវិធីសិក្សាដែលយើងកត់វត្តមាន ប៉ុន្តែនេះសំខាន់ណាស់ ដោយសារនេះជាជីវិតយើងជាគ្រីស្តបរិស័ទ។ សន្តយ៉ូស្ទីនច្បាស់មិនមែនការអប់រំ ចំណេះទូទៅ ទេវវិទ្យា និងមុខវិជ្ជាផ្សេងៗស្រួល ប៉ុន្តែយើងបន្ថែមអធិដ្ឋាន និងលើសពីអធិដ្ឋានទៀតជីវិតជាក្រុម។ ក្នុងជីវិតជាក្រុម នៅពេលដែលយើងលាងចាន នៅពេលយើងហូបបាយ យើងឆ្លើយរៀបចំជាក្រុមដើម្បីរិះគិតពីសំណួរ នេះជាឱកាសមួយដែរដើម្បីស្តាប់គ្នាទៅវិញទៅមក និងម្យ៉ាងដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។

**ចំនុចទីពីរ យើងបានស្តាប់ព្រះជាម្ចាស់ តាមរយៈរបៀបជីវិតរបស់យើងជាប្រចាំថ្ងៃ** ព្រះបន្ទូលរបស់ព្រះជាម្ចាស់កំពុងតែមានអត្ថន័យ កំពុងតែមានខ្លឹមសារសម្រាប់ជីវិតរបស់យើងជាប្រចាំថ្ងៃ និងយើងត្រូវការសួរខ្លួនឯងថា “**ខ្ញុំជាគ្រីស្តបរិស័ទម្នាក់នៅព្រះសហគមន៍ប្រទេសកម្ពុជា ខ្ញុំជានិស្សិតនៃសាលាអប់រំជំនឿសន្តយ៉ូស្ទីន តើខ្ញុំទទួលតួនាទីអ្វីខ្លះ តើខ្ញុំទទួលខុសត្រូវអ្វីខ្លះ នៅក្នុងសង្គមបច្ចុប្បន្ននេះ?**" នេះជាអ្វីដែលយើងត្រូវការគិតពិចារណាដែរ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចចូលនៅក្នុងសង្គម តាមរយៈយើងដោយយើងជាអ្នក

ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់និងចេះអនុវត្តតាម។ ប៉ុន្តែនៅពេលយើងស្តាប់ នៅពេលយើងអនុវត្តព្រះបន្ទូលព្រះជាម្ចាស់ ជាឱកាសមួយដើម្បីឲ្យបងប្អូនឯទៀតៗដែលមិនមែនគ្រីស្តបរិស័ទនៅក្នុងសង្គម នៅកន្លែងធ្វើការ អាចស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរតាមរយៈយើង។ យើងបានស្តាប់ ឧទាហរណ៍ខ្លះៗនៅក្នុងសំណួរទាក់ទងនឹងប្រទេសម៉ាឡេស៊ី និងជាពិសេសយើងអាចគិតថែមទៀតនៅក្នុងឆ្នាំនេះអំពីសំណួរមួយដ៏សំខាន់ **យើងរស់នៅមិនមែននៅក្នុងពិភពមួយដែលមានវប្បធម៌តែមួយ ប៉ុន្តែយើងរស់នៅក្នុងសង្គម នៅក្នុងសង្គមអន្តរវប្បធម៌ យើងធ្វើដូចម្តេចដើម្បីឲ្យវប្បធម៌នីមួយៗអាចចូលជាមួយវប្បធម៌យើង មិនមែនដើម្បីបំផ្លាញវប្បធម៌យើង ប៉ុន្តែដើម្បីឲ្យវប្បធម៌យើងរីកចម្រើនថែមទៀត? ជាពិសេសនៅក្នុងតំបន់អាស៊ានរបស់យើង ដែលបន្តិចម្តងៗយើងចាប់អារម្មណ៍ថែមទៀតអំពីទាំងដប់ប្រទេស យើងធ្វើយ៉ាងម៉េចដើម្បីរស់នៅយ៉ាងសមរម្យ? យ៉ាងសុខដុមរមនានៅក្នុងវប្បធម៌ដែលជាអន្តរវប្បធម៌?** ជាសំណួរមួយដែលយើងអាចសួរ និងយើងអាចធ្វើជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ សម្រាប់សញ្ជាតិនានាដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ដើម្បីរស់ជាមួយគ្នាយ៉ាងសុខសាន្ត។ យើងអាចគិតថែមទៀតអំពីអន្តោរប្រវេសន៍ ដោយសារយើងបាននិយាយអំពីអន្តោប្រវេសន៍មាននៅប្រទេសម៉ាឡេស៊ី នៅក្នុងប្រទេសកម្ពុជាក៏មានច្រើន។ ដូច្នេះនេះជាឱកាសមួយ សម្រាប់យើងដែលជាសាលាសន្តយ៉ូស្ទីនដែរ គិតយ៉ាងម៉េចដើម្បីទទួលស្វាគមន៍ជនបរទេស ដែលជួបជាប្រចាំនៅកន្លែងដែលយើងធ្វើការ និងកន្លែងដែលយើងនៅ។

លើសពីនេះទៀត បើយើងគិតអំពីអន្តោប្រវេសន៍ យើងគិតអំពីកម្មករ ដោយសារតាមពិតជាកម្មករបរទេសធ្វើការនៅប្រទេសម៉ាឡេស៊ី។ តែជាឱកាសមួយ ដើម្បីគិតអំពីកម្មករខ្មែរដែលកំពុងធ្វើការនៅប្រទេសកម្ពុជា។ ថ្ងៃអាទិត្យមុន យើងមានទិវាពលករ និងមានប្រហែលមួយរយហាសិបនាក់ ជាពិសេសស្រីៗដែលបានមក ខ្ញុំគិតថាព្រះសហគមន៍របស់យើងមានសកម្មភាពស្ទើរមែនទែន និងតិចមែនទែនសម្រាប់កម្មករដែលយើងមានសព្វថ្ងៃនៅកម្ពុជា។ សព្វថ្ងៃយើងមានមួយលាននាក់ ហើយក្នុងនេះយើងមានគ្រីស្តបរិស័ទតិច។ **ប៉ុន្តែយើងអាចធ្វើអ្វីខ្លះ ដើម្បីឲ្យពលករអាចស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់បាន?** អ្វីដែលខ្ញុំកំពុងនិយាយ ខ្ញុំសង្ឃឹមអាចទៅជាគំនិតសម្រាប់គម្រោងការប្រកាសដំណឹងល្អដែលយើងរៀបចំនៅខាងមុខ។ យើងត្រូវការគិតអំពីការអប់រំយុវជន ខ្ញុំមិននិយាយតែអំពីក្រុមយុវជននៅក្នុងព្រះសហគមន៍កាតូលិក ប៉ុន្តែសព្វថ្ងៃយុវជននៅក្នុងសង្គមយើង កំពុងរស់នៅក្នុងសង្គមដែលប្រែប្រួលលឿនទំនើប ដែលប្រើបណ្តាញទំនាក់ទំនងសង្គម (Social Media) ដើម្បីធ្វើយ៉ាងម៉េចឲ្យយើងជាគ្រីស្តបរិស័ទ យើងអាចជួយអប់រំយុវជនដែរ។ ខ្ញុំគិតថាជាមួយស៊ីអេសស៊ី ប៉ុន្តែជាមួយយើងដែរអាចរៀបចំវីដេអូខ្លីៗមួយនាទី ពីរនាទី អំពីប្រធានបទមួយដែលទាក់ទងនឹងយុវជនប្រសិនបើមាន យើងទៅរកកន្លែងមួយដែលល្អដូចនៅក្នុងហ្វេសប៊ុក យូធូប គេមើលច្រើនណាស់ ដើម្បីអប់រំអំពីជីវិតប្រចាំ អំពីសីលធម៌ អំពីគ្រឿងញៀន អំពីអ្វីៗទាំងអស់ដែលយើងមើលឃើញសព្វថ្ងៃ ជាបញ្ហាយ៉ាងធំនៅក្នុងសង្គមរបស់យើង ដើម្បីឲ្យព្រះបន្ទូលព្រះជាម្ចាស់ទៅដល់គេដែរ។ ការពារបរិស្ថាន ក៏ជាតួនាទីរបស់ជាគ្រីស្តបរិស័ទ ប្រហែលលើសពីអ្វីៗទាំងអស់ដោយសារដឹងថាព្រះជាម្ចាស់បានបង្កើតមនុស្សលោក ព្រះជាម្ចាស់បានបង្កើតធម្មជាតិ និងបានប្រគល់ឲ្យយើង។ ដូច្នេះយើងជាគ្រិស្តបរិស័ទ ហើយយើងមិនមែននៅឆ្ងាយពីជីវិតប្រចាំនៃសង្គមយើង ប៉ុន្តែយើងចូលនៅក្នុងសង្គម ដើម្បីទៅជាសញ្ញាសម្គាល់នៃវត្តមានព្រះជាម្ចាស់ មានន័យថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាចទទួលបានពីបងប្អូនឯទៀតៗដោយសារយើងដែរ។

**ចំនុចទីបី យើងទទួលតួនាទីមួយ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចស្តាប់ឮថែមទៀតនៅក្នុងព្រះសហគមន៍ប្រចាំរបស់យើង**។ ព្រះសហគមន៍របស់យើងជាព្រះសហគមន៍មួយតូច យើងមានតួនាទីមួយយ៉ាងពិសេស ដោយសារយើងបានសុខចិត្តលះបង់ចោលពេល

វេលាពីរឆ្នាំ ដើម្បីទទួលការអប់រំបន្ថែម។ កុំឲ្យការអប់រំបន្ថែមនេះ មានព្រំដែន មានកំណត់សម្រាប់យើងតែប៉ុណ្ណឹង ជាការអប់រំ ជាព្រះបន្ទូលដែលយើងស្ដាប់ ដើម្បីឲ្យព្រះបន្ទូលនេះទៅដល់ព្រះសហគមន៍នីមួយៗ ហើយជាពិសេសយើងអាចមានគំនិតយ៉ាងច្រើន ដើម្បីធ្វើយ៉ាងម៉េចឲ្យព្រះសហគមន៍របស់យើងថែរក្សាឯកភាពគ្នា ធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះសហគមន៍របស់យើង ដែលជាព្រះសហគមន៍ស្ថិតនៅក្នុងប្រទេសកម្ពុជា អាចសម្រុះសម្រួលគ្នា រួមជាមួយគ្នាជាធ្លុងតែមួយ។ នេះជាតួនាទីរបស់យើង តាមរយៈមេរៀនដែលយើងទទួល ឆ្នាំនេះពេលខ្ញុំនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលដែលខ្ញុំនិយាយអំពីព្រះសហគមន៍ គឺជាឱកាសមួយដើម្បីគិតថែមទៀត ធ្វើយ៉ាងម៉េចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាចអនុវត្តនៅក្នុងព្រះសហគមន៍យើងតែម្ដង ដោយសារស្ដាប់មិនពិបាកទេ អនុវត្តពិបាកណាស់។ អំពីការត្រាស់ហៅដែរ ខ្ញុំជឿថាយើងទាំងអស់ដែលជាគ្រីស្ដបរិស័ទដែលរស់នៅក្នុងព្រះសហគមន៍នេះ ធ្វើយ៉ាងម៉េចដើម្បីឲ្យយុវជនផ្សេងៗអាចគិតអំពីជីវិតជាអ្នកបម្រើព្រះសហគមន៍? នេះមិនមែនលោកឪពុកអាចធ្វើម្នាក់ឯងទេ មិនមែនបងស្រីដែលអាចធ្វើម្នាក់ឯងទេ ប៉ុន្តែយើងជាព្រះសហគមន៍មួយ ដែលលើកទឹកចិត្តយុវជនមួយចំនួន យុវនារីមួយចំនួន ដើម្បីឲ្យគេយល់ថាទោះបីឪពុកម្ដាយគេមកពីពុទ្ធសាសនា ប៉ុន្តែឲ្យគេយល់ថាជីវិតរបស់គេអាចទៅជាជីវិតមួយពិសេស ដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីបម្រើព្រះសហគមន៍អស់មួយជីវិតថែមទៀត។ នៅក្នុងឆ្នាំគ្រួសារនេះ ជាឱកាសមួយដែរសម្រាប់យើង ដើម្បីពិចារណានៅក្នុងនេះមានខ្លះដែលរៀបការហើយ ដែលមានគ្រួសារហើយ និងដើម្បីរិះគិតថែមទៀតថា “**គ្រួសារដ៏វិសុទ្ធជាអ្វី?**” ព្រះនាងម៉ារី សន្តយ៉ូសែប ព្រះយេស៊ូ ប៉ុន្តែយើងក៏អាចទៅជាគ្រួសារគំរូ និងជួយណែនាំថែមទៀត។

**ចំនុចទីបួន ខ្ញុំអញ្ជើញបងប្អូនទាំងអស់ពិចារណា ធ្វើយ៉ាងម៉េចដើម្បីជួយថែមទៀតបងប្អូនដែលទទួលពិធីជ្រមុជទឹកថ្មីៗ មួយឆ្នាំទៅមួយឆ្នាំពន្លកថ្មីបាត់ច្រើនទៅៗ។** ពេលខ្ញុំបើកសន្តយ៉ូស្ទីនជំនាន់ទីមួយ មានពន្លកថ្មីច្រើន ជំនាន់ទីពីរមានខ្លះ ជំនាន់ទីបីចង់អស់ហើយ។ ប៉ុន្តែនេះមានអត្ថន័យថា ពីមួយឆ្នាំទៅមួយឆ្នាំពន្លកថ្មីមួយចំនួនបាត់ច្រើនទៅៗ ពិធីជ្រមុជទឹកច្រើនទៅៗ ប៉ុន្តែមនុស្សនៅបន្តបាត់ច្រើនទៅៗ។ ហើយនេះខ្ញុំគិតថាជាតួនាទីរបស់យើង ដោយសារយើងមកពីព្រះសហគមន៍ដែលមានពន្លកថ្មី ពន្លកថ្មីជាអ្នកដែលទទួលពិធីជ្រមុជទឹកថ្មីៗ នៅក្នុងព្រះសហគមន៍របស់យើងផ្ទាល់មាន។ ដូច្នេះខ្ញុំដែលជាគ្រីស្ដបរិស័ទពីយូរហើយដែលកំពុងរិះគិត ដែលកំពុងជាគ្រីស្ដបរិស័ទរឹងមាំនៅក្នុងជំនឿ នៅក្នុងសេចក្ដីស្រឡាញ់ តើយើងធ្វើយ៉ាងណាដើម្បីទាក់ទាញ ដើម្បីស្រឡាញ់ ដើម្បីណែនាំឲ្យពន្លកថ្មីបន្តរស់នៅក្នុងព្រះសហគមន៍ និងបន្តអធិដ្ឋាន នៅជាប់ជាមួយព្រះជាម្ចាស់?

ដូច្នេះយើងគិត ដើម្បីទទួលព្រះបន្ទូលនេះសម្រាប់ពេញមួយឆ្នាំ និងអនុវត្តរបៀបពិសេសសម្រាប់យើង “**អ្នកណាស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយអនុវត្តតាម គឺអ្នកនោះហើយដែលមានសុភមង្គលពិតមែន**”។ អាម៉ែន៕